# គណៈកម្មការអធិការកិច្ចនៃ ធនាគារពិភពលោក

*ជាកន្លែងស្តាប់បញ្ហាកង្វល់របស់អ្នក*



The Inspection Panel | THE WORLD BANK
IBRD • IDA | WORLD BANK GROUP

# តើជាអ្វី

## តើគណៈកម្មការអធិការកិច្ច គឺជាអ្វី ?

គណៈកម្មការអធិការកិច្ច ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ ដោយក្រុមប្រឹក្សាប្រតិបត្តិនៃធនាគារពិភពលោក។ គណៈកម្មការនេះគឺជាយន្តការបណ្តឹងឯករាជ្យមួយ សម្រាប់ប្រជាពលរដ្ឋដែលជឿថា ពួកគេបានរងគ្រោះថ្នាក់ ឬ ទំនងនឹងរងគ្រោះថ្នាក់ដោយសារគម្រោងដែលទទួលបាន មូលនិធិគាំទ្រពីធនាគារពិភពលោក។ គណៈកម្មការនេះមានសមាសភាពចូលរួមពីសមាជិកចំនួនបីរូប មកពីប្រទេសផ្សេងៗគ្នាដែលត្រូវបានជ្រើសរើសដោយផ្អែកលើបទពិសោធន៍ការងារពហុវិស័យរបស់ពួកគេនៅក្នុងវិស័យការងារអភិវឌ្ឍ ព្រមទាំងភាពឯករាជ្យ និង សុចរិតភាពរបស់ពួកគេ។ សមាជិកនីមួយៗបម្រើអាណត្តិការងាររយៈពេលប្រាំឆ្នាំ និង មិនអាចបន្តបានឡើយ។ គណៈកម្មការនេះមានការគាំទ្រពីលេខាធិការដ្ឋានមួយ ដែលមានទីតាំងស្ថិតនៅក្នុងយន្តការគណនេយ្យភាព របស់ធនាគារពិភពលោកនៅឯស្នាក់ការកណ្តាលរបស់ធនាគារពិភពលោក ក្នុងទីក្រុងវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក។ គណៈកម្មការនេះរាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាប្រតិបត្តិរបស់ធនាគារពិភពលោក និង មានភាពឯករាជ្យដាច់ដោយឡែកពីថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក។



## ដោយរបៀបណា

## តើដំណើរការរបស់គណៈកម្មការនេះ ប្រព្រឹត្តទៅដូចម្តេច?

ជនទាំងឡាយណាដែលមានសមាជិកចាប់ពីពីរនាក់ឡើងទៅ សំដៅហៅថា"អ្នកស្នើសុំ" អាចដាក់បណ្តឹងទៅគណៈកម្មការនេះបាន។ តាមរយៈដំណើរការរបស់ខ្លួន គណៈកម្មការនេះធ្វើការវាយតម្លៃ ថាតើធនាគារពិភពលោកបានអនុវត្តស្របតាមគោលនយោបាយ និង នីតិវិធីផ្ទៃក្នុងរបស់ខ្លួនដែលត្រូវបានរចនាឡើងដើម្បីការពារសុវត្ថិភាពមនុស្ស និង បរិស្ថានដែរឬទេ។ គណៈកម្មការនេះក៏វាយតម្លៃផងដែរថាតើមានភាពមិនអនុលោមណាមួយដែលបានរួមចំណែកឬអាចរួមចំណែកនៅពេលអនាគតបង្កឱ្យមានគ្រោះថ្នាក់ដូចមានរៀបរាប់នៅក្នុងបណ្តឹងដែរឬទេ។ នីតិវិធីប្រតិបត្តិការរបស់គណៈកម្មការនេះ (អាចរកមើលបាននៅឯ www.inspectionpanel.org) ពន្យល់អំពីដំណាក់កាលផ្សេងៗគ្នានៅក្នុងដំណើរការរបស់គណៈកម្មការរួមទាំងរបៀបដែលគណៈកម្មការនេះកំណត់ថាបណ្តឹងមួយអាចទទួលយកបាននិងមានលក្ខខណ្ឌសមស្រប ដើម្បីធ្វើការពិនិត្យបន្តផងដែរ។

ដំណើរការរបស់គណៈកម្មការនេះក៏ផ្តល់ឱកាសសម្រាប់ការប្រាស្រ័យទាក់ទងប្រកបដោយភាពស្ថាបនាផងដែរ រវាងអ្នកស្នើសុំ និង ធនាគារពិភពលោក ក្នុងគោលបំណងឆ្លើយតបនិងដោះស្រាយបញ្ហា ដើម្បីជាប្រយោជន៍ដល់គ្រប់ភាគីដែលពាក់ព័ន្ធ។ រាល់របាយការណ៍ទាំងអស់ដែលត្រូវបានរៀបចំឡើងរួមទាំងបណ្តឹងបឋមត្រូវបានផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែអត្តសញ្ញាណរបស់អ្នកស្នើសុំ នឹងត្រូវរក្សាជាការសម្ងាត់ ប្រសិនបើមានការស្នើសុំបែនេះ។ សេចក្តីសង្ខេបអំពីដំណើរការរបស់គណៈកម្មការនេះមានបង្ហាញក្នុងរូបភាពនៅលើក្របទំព័រខាងក្រោយ។

## ននរណា

## តើនរណាអាចដាក់ពាក្យបណ្តឹងបាន?

ជនរងផលប៉ះពាល់ចាប់ពីពីរនាក់ឡើងទៅ នៅក្នុងប្រទេសដែលធនាគារពិភពលោកគាំទ្រគម្រោង អាចដាក់ពាក្យបណ្តឹង (ជាផ្លូវការហៅថា "សំណើសុំធ្វើអធិការកិច្ច")។ អ្នកស្នើសុំអាចផ្ញើសំណើនេះដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាងណាមួយ។



# តើជាអ្វី

## អ្នកស្នើសុំអាចប្ដឹងអំពីអ្វីខ្លះ?

គណៈកម្មការអធិការកិច្ច បានដោះស្រាយបញ្ហាគ្រោះថ្នាក់ ឬ គ្រោះថ្នាក់សក្ដានុពលជាច្រើនប្រភេទផ្សេងៗគ្នា ចំពោះមនុស្ស ឬ បរិស្ថានក្នុងការឆ្លើយតបទៅនឹងសំណើសុំឱ្យធ្វើអធិការកិច្ច។ ករណីមួយចំនួនពាក់ព័ន្ធទៅនឹងគ្រោះថ្នាក់ចំពោះជីវភាពរស់នៅរបស់មនុស្ស ឬ ភាពវិចវិលបរិស្ថានដែលបង្កដោយគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ គណៈកម្មការក៏បានពិចារណាផងដែរអំពីគម្រោងនានា ដែលពាក់ព័ន្ធនឹងការផ្លាស់ប្ដូរទីលំនៅដោយបង្ខំ (ឧទាហរណ៍ដោយសារការសាងសង់ទំនប់ ផ្លូវ បំពង់បង្ហូរទីលានចាក់សំរាម ឬ រោងចក្រអគ្គិសនី) គម្រោងដែលប៉ះពាល់សិទ្ធិ និង ប្រយោជន៍របស់ជនជាតិដើមភាគតិច (ដូចជា សិទ្ធិកាន់កាប់ដីធ្លីតាមបែបប្រពៃណី ទីកន្លែងដែលមានសារៈសំខាន់ចំពោះវប្បធម៌ ឬ ជីវភាពរស់នៅ) និង គម្រោងដែលប៉ះពាល់ដល់បរិស្ថាន កន្លែងវប្បធម៌ និង ជម្រកធម្មជាតិ(ឧទាហរណ៍ការបំពុលខ្យល់ និងទឹក សម្ពាធទៅលើធនធានទឹក ផលប៉ះពាល់អវិជ្ជមានទៅលើតំបន់ដីសើម ការបាត់បង់ព្រៃឈើ និង ការបាត់បង់ជីវចម្រុះ)។គណៈកម្មការក៏បានដោះស្រាយករណីចោទប្រកាន់អំពីបញ្ហាអំពើហិង្សាយេនឌ័រនៅក្នុងគម្រោង និង សិទ្ធិរបស់សហគមន៍រងផលប៉ះពាល់ នៅក្នុងការពិគ្រោះយោបល់ និង ការចូលរួមប្រកបដោយអត្ថន័យ សម្រាប់ការរៀបចំផែនការ និង ការអនុវត្តគម្រោង រួមទាំងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានព័ត៌មានផងដែរ។ រាល់ប្រភេទគ្រោះថ្នាក់ទាំងនេះ ឬ គ្រោះថ្នាក់សក្ដានុពល ត្រូវបានគណៈកម្មការយកមកពិនិត្យឡើងវិញនៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយនិង នីតិវិធីប្រតិបត្តិការរបស់ធនាគារពិភពលោក។

អាណត្តិការងាររបស់គណៈកម្មការនេះ មិនគ្របដណ្ដប់លើបញ្ហាទាក់ទងនឹងលទ្ធកម្ម ទំនិញ ឬ សេវាកម្ម អំពើពុករលួយ ឬ បញ្ហាដែលគណៈកម្មការបានដោះស្រាយរួចនៅក្នុងករណីកន្លងមកឡើយ លើកលែងតែមានការបង្ហាញភស្តុតាងថ្មី ឬ ស្ថានភាពថ្មី។ បញ្ហាពាក់ព័ន្ធនឹងការសង្ស័យថាមានករណីលួចបន្លំ ឬ អំពើពុករលួយ ពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មមិនត្រឹមត្រូវនៅក្នុងគម្រោងដែលទទួលបានការគាំទ្រពីធនាគារពិភពលោក ឬ ពាក់ព័ន្ធនឹងការប្រព្រឹត្តខុសឆ្គងរបស់បុគ្គលិកធនាគារពិភពលោក ទាក់ទងនឹងការចោទប្រកាន់អំពីករណីលួចបន្លំ និង អំពើពុករលួយ គប្បីត្រូវបានរាយការណ៍ទៅបណ្ដាញទូរស័ព្ទទាន់ហេតុការណ៍របស់ធនាគារពិភពលោកសម្រាប់ករណីលួចបន្លំ និង អំពើពុករលួយ៖ www.worldbank.org/integrity។

អាណត្តិការងាររបស់គណៈកម្មការនេះ គ្របដណ្ដប់លើគម្រោងទទួលបានហិរញ្ញប្បទានគាំទ្រពីធនាគារអន្តរជាតិសម្រាប់ការស្ថាបនាឡើងវិញ និង ការអភិវឌ្ឍ (IBRD) និងសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) នៃក្រុមធនាគារពិភពលោក បន្ថែមពីលើមូលនិធិបរធនបាលកិច្ចដែលគ្រប់គ្រងដោយធនាគារពិភពលោក។ បណ្ដឹងអំពីគម្រោងដែលគាំទ្រដោយសារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី(MIGA) ត្រូវបានដោះស្រាយដោយការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (CAO)។ ព័ត៌មានបន្ថែមអំពីការិយាល័យ CAO អាចរកបានតាមរយៈ www.cao-ombudsman.org។

## តើត្រូវដាក់ពាក្យបណ្តឹងដោយរបៀបណា ?

ដោយរបៀបណា

ពាក្យបណ្តឹង (សំណើសុំធ្វើអធិការកិច្ច) អាចធ្វើឡើងតាមរយៈលិខិត ឬ អ៊ីមែល។ សូមកត់សម្គាល់ថា បណ្តឹងនេះអាចសរសេរដោយពលរដ្ឋណាម្នាក់ ដោយមិនចាំបាច់មានជំនួយពីអ្នកជំនាញ ឬ មេធាវី។ បណ្តឹងនេះគប្បីមានការចុះហត្ថលេខា និង ត្រូវមានព័ត៌មានខាងក្រោម។

- ឈ្មោះរបស់អ្នក (ត្រូវមានអ្នកស្នើសុំចាប់ពីពីរនាក់ឡើងទៅ) និង កន្លែងដែលអ្នករស់នៅ។ ប្រសិនបើអ្នកចាត់តាំងបុគ្គល ឬ អង្គការណាមួយធ្វើជាអ្នកតំណាងឱ្យអ្នក អ្នកត្រូវបញ្ចូលឈ្មោះ ព្រមជាមួយនឹងលិខិតប្រគល់សិទ្ធិមួយច្បាប់ ដែលមានចុះហត្ថលេខា ដើម្បីឱ្យបុគ្គល ឬ អង្គការនោះដើរតួនាទីជាអ្នកតំណាងរបស់អ្នក។
- ឈ្មោះគម្រោងដែលបានទទួលការគាំទ្រពីធនាគារពិភពលោក (ប្រសិនបើអ្នកដឹង)ដែលអ្នកមានការព្រួយបារម្ភចំពោះគម្រោងនោះ។
- ការពណ៌នាអំពីគ្រោះថ្នាក់ដែលអ្នក ឬ បរិស្ថានដែលអ្នករស់នៅ បានជួបប្រទះ ឬ គ្រោះថ្នាក់ ដែលអ្នកជឿថាទំនងនឹងកើតឡើងដោយសារតែគម្រោងនោះ។
- ការពណ៌នា (ក្នុងកម្រិតវិសាលភាពដែលអ្នកដឹង) អំពីហេតុអ្វីបានជាអ្នកជឿថាធនាគារពិភពលោកមិនបានអនុវត្តតាមគោលនយោបាយ និង នីតិវិធីរបស់ខ្លួន និង របៀបដែលការមិនបានតាមគោលនយោបាយ និង នីតិវិធីនេះ បានបង្កឱ្យមានគ្រោះថ្នាក់(ប៉ុន្តែ សូមកត់សម្គាល់ថា សំណើសុំធ្វើអធិការកិច្ចមិនចាំបាច់ត្រូវបញ្ជាក់អំពីគោលនយោបាយជាក់លាក់ណាមួយរបស់ធនាគារពិភពលោក ដែលត្រូវពិចារណាឡើយ)។
- ការពន្យល់ថា តើអ្នកបានជូនដំណឹងទៅធនាគារពិភពលោកអំពីបញ្ហាកង្វល់របស់អ្នកនៅពេលណា និង ដោយរបៀបណា និង ហេតុអ្វីបានជាអ្នកមិនពេញចិត្តទៅនឹងការឆ្លើយតបរបស់ធនាគារពិភពលោក។
- ប្រសិនបើអ្នកចង់អ្នកអាចពណ៌នាអំពីសកម្មភាពដែលអ្នកគិតអាចដោះស្រាយបញ្ហាកង្វល់របស់អ្នកបាន។

ភាសាអង់គ្លេសគឺជាភាសាផ្លូវការសម្រាប់ដំណើរការរបស់គណៈកម្មការនេះប៉ុន្តែអ្នកអាចដាក់ពាក្យបណ្តឹងជាភាសារបស់អ្នកបាន។អ្នកអាចដាក់បណ្តឹងក្នុងទម្រង់ជាក្រដាសទៅអសយដ្ឋានប្រៃសណីយ៍របស់យើង(សូមមើលព័ត៌មាននៅលើក្របខាងក្រោយ) ឬ ក្នុងទម្រង់អេឡិចត្រូនិកទៅ ipanel@worldbank.org ឬ accountability@worldbank.org។

អ្នកអាចរកគំរូទម្រង់ពាក្យបណ្តឹងនៅក្នុងគេហទំព័ www.inspectionpanel.org របស់គណៈកម្មការបាន រួមជាមួយនឹងព័ត៌មានដទៃទៀតអំពីគណៈកម្មការ។ ប្រសិនបើអ្នកមានសំនួរបន្ថែមទៀត អ្នកអាចស្វែងរកចម្លើយនៅលើគេហទំព័រនេះ ឬ អ្នកអាចទាក់ទងលេខាធិការដ្ឋានរបស់គណៈកម្មការដោយផ្ទាល់ តាមរយៈអ៊ីមែល ឬ ទូរស័ព្ទ (សូមមើលព័ត៌មានទំនាក់ទំនងនៅលើក្របខាងក្រោយ)។ លេខាធិការដ្ឋានរបស់គណៈកម្មការ ក៏អាចជួយឱ្យអ្នកយល់ផងដែរអំពីលក្ខខណ្ឌតម្រូវមូលដ្ឋាន ដើម្បីឱ្យបណ្តឹងមួយអាចទទួលយកបាន។

តើអ្វីខ្លះ

## តើអ្នកអាចរំពឹងថានឹងទទួលបានអ្វីខ្លះពីដំណើរការរបស់គណៈកម្មការ ?

### ការដាក់បណ្ដឹងទៅគណៈកម្មការ អាចៈ

- នាំឱ្យមានការសម្រេចពីគណៈកម្មការ ថាតើការរំលោភបំពានទៅលើគោលនយោបាយ និង នីតិវិធីរបស់ធនាគារពិភពលោក មានទំនាក់ទំនងទៅនឹងគ្រោះថ្នាក់ដែលបានចោទប្រកាន់ដែរឬទេ។
- ជួយទាញការផ្ដោតយកចិត្តទុកដាក់ទៅលើគ្រោះថ្នាក់ ឬ គ្រោះថ្នាក់ជាសក្ដានុពល និង បង្កើតជាមេរៀនដែលអាចជួយបញ្ចៀសគ្រោះថ្នាក់បែបនេះនៅក្នុងគម្រោងរបស់ធនាគារពិភពលោក នៅពេលអនាគតបាន។
- នាំឱ្យមានចំណាត់ការពីថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកពីដំបូងនៅក្នុងដំណើរការដើម្បីកែតម្រូវទៅលើគ្រោះថ្នាក់ដែលបានកើតឡើង ឬ ដោយសារផែនការសកម្មភាព របស់ថ្នាក់គ្រប់គ្រង (MAP) និង សេចក្ដីសម្រេច និង ការចង្អុលទិសរបស់ក្រុមប្រឹក្សាភិបាល នៅចុងបញ្ចប់នៃការស៊ើបអង្កេតរបស់គណៈកម្មការ។
- នាំឱ្យគណៈកម្មការឈានទៅធ្វើការពិនិត្យផ្ទៀងផ្ទាត់ថា សកម្មភាពកែតម្រូវនៅក្នុង MAP ត្រូវបានអនុវត្តដោយជោគជ័យ។ (ដំណើរការនេះស្រដៀងគ្នាទៅនឹង "ការត្រួតពិនិត្យ" ដែលធ្វើឡើងដោយយន្តការគណនេយ្យភាពឯករាជ្យដទៃទៀត។)
- នាំឱ្យមានដំណើរការដោះស្រាយវិវាទមួយ ប្រសិនបើមានការឯកភាពពីអ្នកស្នើសុំ និង ប្រទេសដែលខ្ចីឥណទានសម្បទាន។

### ការដាក់បណ្ដឹងទៅគណៈកម្មការ នឹងមិនៈ

- ធានាថាគ្រោះថ្នាក់បង្កឡើងដោយគម្រោងដែលទទួលបានមូលនិធិគាំទ្រពីធនាគារពិភពលោក នឹងត្រូវបញ្ចប់ ឬ ត្រូវបានរារាំងឡើយ អាស្រ័យដោយគណៈកម្មការមិនមែនជាតុលាការដែលមានអំណាចអនុវត្តដីកានោះទេ។ បើទោះជាដូច្នេះក្ដី គណៈកម្មការនេះរាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាប្រតិបត្តិរបស់ធនាគារពិភពលោក ហើយថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក មានការទទួលខុសត្រូវដោះស្រាយ និង ឆ្លើយតបទៅនឹងគំហើញរបស់គណៈកម្មការ។
- កំណត់ថាបុគ្គលិករបស់ធនាគារពិភពលោក មានទោសកំហុស ឬគ្មានទោសកំហុសឡើយ ដោយឡែក គណៈកម្មការពិនិត្យទៅលើបញ្ហាភាពអនុលោមរបស់ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោកជារួម។
- នាំឱ្យមានការស៊ើបអង្កេតទៅលើរដ្ឋាភិបាលដែលខ្ចីឥណទានសម្បទាននោះទេ អាស្រ័យដោយគណៈកម្មការនេះស៊ើបអង្កេតទៅលើធនាគារពិភពលោក មិនមែនអ្នកខ្ចីឥណទានសម្បទាននោះទេ។
- នាំឱ្យឈានទៅរកការព្យួរ ឬ ការលុបចោលគម្រោងដោយស្វ័យប្រវត្តិឡើយ (វាជាការសម្រេចចិត្តរបស់ធនាគារពិភពលោក)។

ហេតុអ្វី

### ហេតុអ្វីត្រូវមានគណៈកម្មការនេះ ?

បេសកកម្មរបស់ធនាគារពិភពលោក គឺដើម្បីជួយដល់បណ្ដាប្រទេសនានាលុបបំបាត់ភាពក្រីក្រ និងបង្កើតឱ្យមានវិបុលភាពរួមគ្នា។ គម្រោង និង កម្មវិធីអភិវឌ្ឍន៍នានា មានបំណងនាំមកនូវការផ្លាស់ប្ដូរជាវិជ្ជមាន ប៉ុន្តែ ការអនុវត្តគម្រោង និង កម្មវិធីទាំងនោះ មានពាក់ព័ន្ធនឹងហានិភ័យមួយចំនួន។ បើទោះបីជាគ្រប់គ្នាមានចេតនាល្អបំផុតក្ដី ក៏មនុស្ស និង បរិស្ថាននៅតែអាចរងគ្រោះថ្នាក់។ ធនាគារពិភពលោកមានគោលនយោបាយមួយចំនួន ដើម្បីជួយបញ្ចៀសលទ្ធផលបែបនេះ ប៉ុន្តែបើទោះជាដូច្នេះក៏ដោយ ក៏បញ្ហាមួយចំនួននៅតែបន្តគ្មានការទទួលស្គាល់ ឬ គ្មានការដោះស្រាយ។ ក្នុងស្ថានភាពបែបនេះ វិធីមួយដើម្បីឱ្យបញ្ហាកង្វល់នានាទទួលបានការយកចិត្តទុកដាក់ គឺប្រជាពលរដ្ឋត្រូវនិយាយអំពីបញ្ហាកង្វល់ទាំងនោះចេញមក។ តាមរយៈដំណើរការសហការគ្នាមួយ គណៈកម្មការអាចជួយឱ្យសម្លេង និង បញ្ហាកង្វល់របស់ប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវបានគេស្ដាប់ឮ និង ដោះស្រាយ។



# ដំណាក់កាលនានានៃកិច្ចដំណើរការរបស់គណៈកម្មការអធិការកិច្ច

## ១ ការទទួលសំណើ និងការសម្រេចទៅលើការចុះបញ្ជី

- គណៈកម្មការជូនដំណឹងទៅសាធារណជនថាខ្លួនបានទទួលសំណើសុំធ្វើអធិការកិច្ច តាមរយៈសេចក្ដីជូនដំណឹងមួយអំពីការទទួលបានសំណើនៅលើគេហទំព័ររបស់ខ្លួន។
- បន្ទាប់ពីទទួលបានសំណើក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការរួចមក គណៈកម្មការសម្រេចថាតើត្រូវចេញសេចក្ដីជូនដំណឹងអំពីការចុះបញ្ជីសំណើ ឬ សេចក្ដីជូនដំណឹងអំពីការមិនចុះបញ្ជីសំណើ។

## ២ លក្ខខណ្ឌសមស្រប និងអនុសាសន៍របស់គណៈកម្មការ

- ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក ឆ្លើយតបក្នុងរយៈពេល២១ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានចុះបញ្ជីរួចរាល់។
- ដំណើរទស្សនកិច្ចរបស់គណកម្មការ ក្នុងករណីចាំបាច់។
- បន្ទាប់ពីទទួលបានការឆ្លើយតបពីថ្នាក់គ្រប់គ្រង ក្នុងរយៈពេល២១ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មការផ្ដល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលនៃនាយកប្រតិបត្តិ ថាតើចាំបាច់ត្រូវធ្វើការស៊ើបអង្កេតមួយ ដែរឬទេ។
- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មការ (ជាធម្មតាក្នុងរយៈពេល១០ថ្ងៃ នៃថ្ងៃធ្វើការ)។

## ៣ ការបញ្ជូនទៅផ្នែកដោះស្រាយវិវាទ (DR)

- ប្រសិនបើមានការអនុម័តឱ្យធ្វើការស៊ើបអង្កេតមួយ លេខានៃយន្តការគណនេយ្យភាពរបស់ធនាគារពិភពលោក ផ្ដល់ជម្រើសដោះស្រាយវិវាទជូនដល់អ្នកស្នើសុំ និង អ្នកខ្ចីឥណទានសម្បទាន។
- ប្រសិនបើភាគីទាំងសងខាងឯកភាពទទួលយកជម្រើសដោះស្រាយវិវាទ (DR) គណៈកម្មការផ្អាកការស៊ើបអង្កេតរបស់ខ្លួនសិន។
- ដំណើរការដោះស្រាយវិវាទ មានរយៈពេលអតិបរមាចំនួនមួយឆ្នាំ (អាចបន្តបានប្រាំមួយខែ)។

## ៤ ការស៊ើបអង្កេត

- ប្រសិនបើភាគីទាំងសងខាងមិនជ្រើសរើសយកការដោះស្រាយវិវាទ ឬ ការដោះស្រាយវិវាទមិនទទួលបានជោគជ័យ គណៈកម្មការចាប់ផ្ដើមការស៊ើបអង្កេតរបស់ខ្លួន។
- ដំណើរទស្សនកិច្ចស៊ើបអង្កេតរបស់គណៈកម្មការ។
- គណៈកម្មការដាក់ជូនរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួនទៅក្រុមប្រឹក្សាភិបាលនៃនាយកប្រតិបត្តិ (គ្រោងបញ្ចប់របាយការណ៍នេះក្នុងរយៈពេលប្រាំមួយខែ ក្រោយពេលដាក់ចេញនូវផែនការស៊ើបអង្កេតរបស់ខ្លួន)។

## ៥ រយៈពេលក្រោយស៊ើបអង្កេត

- របាយការណ៍ស៊ើបអង្កេតរបស់គណៈកម្មការ ត្រូវបានចែករំលែកជាមួយអ្នកស្នើសុំ ក្រោមមូលដ្ឋាននៃការរក្សាការសម្ងាត់។
- ថ្នាក់គ្រប់គ្រងរបស់ធនាគារពិភពលោក ដាក់ជូននូវរបាយការណ៍ និង អនុសាសន៍របស់ខ្លួន (ក្នុងរយៈពេលប្រាំមួយសប្ដាហ៍ បន្ទាប់ពីទទួលបានរបាយការណ៍ស៊ើបអង្កេត)។
- ការពិភាក្សា និង ការអនុម័តរបស់ក្រុមប្រឹក្សាភិបាលនៃនាយកប្រតិបត្តិ ទៅលើផែនការសកម្មភាពរបស់ថ្នាក់គ្រប់គ្រង (MAP)។

## ៦ ការផ្ទៀងផ្ទាត់អំពីការអនុវត្ត MAP

- យោងតាមលក្ខណៈវិនិច្ឆ័យ និង គំរូសមាមាត្រដែលមានមូលដ្ឋានផ្អែកលើហានិភ័យ និង តាមរយៈមតិយោបល់ពីផ្នែកសវនកម្មផ្ទៃក្នុងនៃក្រុមធនាគារពិភពលោក (GIA) គណៈកម្មការអាចផ្ដល់អនុសាសន៍ឱ្យពិនិត្យផ្ទៀងផ្ទាត់ទៅលើការអនុវត្ត MAP ដែលបានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល។
- ដោយមានការអនុម័ត គណៈកម្មការផ្ទៀងផ្ទាត់ទៅលើការអនុវត្តចំណាត់ការរបស់ថ្នាក់គ្រប់គ្រង ដែលដោះស្រាយនូវអ្វីដែលគណៈកម្មការបានរកឃើញ ដោយឡែក GIA ជាអ្នកពិនិត្យផ្ទៀងផ្ទាត់ទៅលើចំណាត់ការរបស់ថ្នាក់គ្រប់គ្រង ដែលសំដៅដោះស្រាយបញ្ហាអភិបាលកិច្ចរបស់ធនាគារពិភពលោក។
- នៅចុងបញ្ចប់នៃដំណើរការ គណៈកម្មការដាក់ជូនរបាយការណ៍ពិនិត្យផ្ទៀងផ្ទាត់ ទៅក្រុមប្រឹក្សាភិបាល។

**គណៈកម្មការអធិការកិច្ច**
1818 H Street NW, Mail Stop: MC10-1007
Washington, DC 20433 U.S.A.
ទូរស័ព្ទ៖ 202 458 5200
ទូរស័ព្ទ៖ 202 522 0916
អ៊ីមែល៖ accountability@worldbank.org
គេហទំព័រ៖ www.inspectionpanel.org

ស្វែងរកយើងខ្ញុំនៅលើទំព័រហ្វេសប៊ុក

The Inspection Panel | THE WORLD BANK
IBRD • IDA | WORLD BANK GROUP